ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ឆ្នាំង**

-សំណុំរឿងព្រហ្មទណ្ឌលេខ ៧៣១
ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣
-សំណុំរឿងជំនុំជម្រះផ្ទាល់លេខ ៣៧
ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤
-សាលក្រមលេខ ២៨ (ញ)
ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០២៤

# សាលក្រម
## ក្នុងនាមប្រជារាស្ត្រខ្មែរ

-សាលាដំបូងខេត្តកំពង់ឆ្នាំង បានបើកសវនាការជាសាធារណៈ នៅសាលសវនាការនៃសាលាដំបូងខេត្តកំពង់ឆ្នាំង

-កាលបរិច្ឆេទបើកសវនាការ ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៤ ម៉ោង១៤៖៣០នាទីរសៀល។

-កាលបរិច្ឆេទប្រកាសសាលក្រម ថ្ងៃទី០២ ខែមេសា ឆ្នាំ២០២៤ ម៉ោង ១៥និង០០នាទីរសៀល។

-ដោយមានសមាសភាពដូចខាងក្រោម៖

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តកំពង់ឆ្នាំង

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ៦១២ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] ហ៊ីន ហៅ គ្រុយ ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើត ភូមិ[redacted] ខេត្តកំពង់ឆ្នាំង ទីលំនៅបច្ចុប្បន្ន ភូមិ[redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] ហុន "ស" ម្តាយឈ្មោះ[redacted] យ៉ូត "រ" ប្រពន្ធឈ្មោះ [redacted] សុផា "រ" មានកូន ០២ នាក់ ប្រវត្តិផ្តន្ទាទោសដោយតុលាការ "ធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសដាក់ ពន្ធនាគារចំនួន ០៦ ខែ ពីបទ ធ្វើឱ្យខូចខាតដោយចេតនា" ។ (ក្រៅឃុំ)

២.ឈ្មោះ [redacted] សុផា ហៅ មុំ ភេទស្រី អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើត ភូមិ[redacted] ខេត្តកំពង់ឆ្នាំង ទីលំនៅបច្ចុប្បន្ន ភូមិ[redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] ស៊ីថូ "រ" ម្តាយឈ្មោះ [redacted] សាផាត "រ" ប្តីឈ្មោះ [redacted] ហ៊ីន "រ" មានកូន ០២ នាក់ ប្រវត្តិផ្តន្ទាទោសដោយតុលាការ "ធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធ នាគារចំនួន ០៦ ខែ ពីបទ ធ្វើឱ្យខូចខាតដោយចេតនា"។ (ក្រៅឃុំ)

មានលោក [redacted] ជាមេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted] ហ៊ីន និងឈ្មោះ [redacted] សុផា។

ជាប់ចោទពីបទ: **រំលោភកាន់កាប់អចលនវត្ថុដោយចេតនា** ប្រព្រឹត្តនៅភូមិស្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ រហូតដល់បច្ចុប្បន្ន បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៤៨ និងមាត្រា ២៥៣ នៃច្បាប់ស្តីពីភូមិបាល។

## ជនរងគ្រោះ

ឈ្មោះ [redacted]សាមិត្ត ភេទស្រី អាយុ៧៩ឆ្នាំ សញ្ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិស្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

## ដើមបណ្តឹងរដ្ឋប្បវេណី

ឈ្មោះ [redacted]ផន ភេទប្រុស អាយុ៦៤ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្ននៅភូមិស្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted]សុផា (ស), ម្តាយឈ្មោះ [redacted] កាន់ (រ) ប្រពន្ធឈ្មោះ [redacted]សាមឿន (រ) ,មានកូន០៤នាក់ ។

តាមដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ ១៤/២០២៤ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។

-បានឃើញ របាយការណ៍សរុប លេខ ១០៥/០២៣ រ.ប.ក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះផ្ទាល់លេខ ៥០/២៤ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ របស់ឯកឧត្តមប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង។

## ដំណើររឿងនៃអង្គហេតុដូចតទៅ

កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្ថិតនៅភូមិក្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ឈ្មោះ [redacted] សុផល ភេទប្រុស អាយុ៦០ឆ្នាំ ជនជាតិខ្មែរ បានលួចលក់ដីដែល ជាកម្មសិទ្ធិរបស់ជនរងគ្រោះឈ្មោះ [redacted]សាមិត្ត ភេទស្រី អាយុ៧៩ឆ្នាំ ជនជាតិខ្មែរ ឱ្យទៅឈ្មោះ [redacted] ហ៊ុន ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] សុផា ភេទស្រី អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ អស់ទំហំ ៧ ម៉ែត្រ និងបណ្តោយ ៣៥ម៉ែត្រ ក្រោយមកជនរងគ្រោះឈ្មោះ [redacted]សាមិត្ត ក៏បានដាក់ពាក្យប្តឹងលើឈ្មោះ [redacted]សុផល ហើយត្រូវបានតុលាការខេត្តកំពង់ឆ្នាំងសម្រេចផ្តន្ទាទោសតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ១២ "ខ" ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ដាក់ពន្ធនាគារកំណត់រយៈពេល ១ (មួយ) ឆ្នាំ ពីបទ លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន ដោយឡែកឈ្មោះ [redacted] ហ៊ុន និងប្រពន្ធឈ្មោះ [redacted] សុផា ដែលបានទិញ ដីពីឈ្មោះ ចិ សុផល ក៏ត្រូវបានឈ្មោះ [redacted] សាមិត្ត ប្តឹងពីបទ កាប់បំផ្លាញដើមត្នោត និងដើមអំពិល នៅលើដីដែលបានទិញនោះអស់ចំនួន ០៤ ដើម រហូតដល់តុលាការខេត្តកំពង់ឆ្នាំងសម្រេចផ្តន្ទាទោសអ្នកទាំងពីរ ដាក់ពន្ធនាគារចំនួន ៦ (ប្រាំមួយ) ខែ ក្នុងម្នាក់ៗតែទោសនេះត្រូវអនុវត្តព្យួរធម្មតា ពីបទ ធ្វើឱ្យខូចខាត ដោយចេតនា ប្រព្រឹត្តនៅចំណុចភូមិស្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១២ ខែ ឧសភា ឆ្នាំ២០២១ តាមសាលក្រមព្រហ្មទណ្ឌលេខ ១៨៧ "ច" ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ តែទោះបីជា តុលាការបានសម្រេចសេចក្តីរួចហើយក៏ដោយក៏ឈ្មោះ [redacted] ហ៊ុន និងឈ្មោះ [redacted] សុផា នៅតែមិនចាកចេញ និងបានកាន់កាប់ដីលើទីតាំងដែលបានទិញដោយខុសច្បាប់នោះរហូតមកដល់សព្វថ្ងៃ ទើបនៅថ្ងៃទី១១ ខែ កក្កដា ឆ្នាំ២០២៣ ឈ្មោះ [redacted]សាមិត្ត ដែលមានបញ្ហាជម្ងឺត្រចៀកថ្លង់ស្តាប់មិនឮ និងមានវ័យចាស់ជរាផង ក៏បានផ្ទេរសិទ្ធិឱ្យកូនប្រសារឈ្មោះ [redacted]ផន ដាក់ពាក្យប្តឹងទៅសមត្ថកិច្ចកងរាជអាវុធហត្ថខេត្តកំពង់ឆ្នាំង ដើម្បីចាត់ការតាមច្បាប់។



Scanned with CamScanner

## នាពេលសវនាការ

១-ជនរងគ្រោះឈ្មោះ [redacted] សាមិត្ត បានឆ្លើយនៅដំណាក់កាលអយ្យការថា៖ ខ្លួនសូមជម្រាបតំណាងអយ្យការថា ខ្លួនបច្ចុប្បន្នមានជំងឺត្រចៀកទាំងសងខាងដោយមិនអាចស្តាប់ឮបានទាំងស្រុង តែអាចអានអក្សរ និងនិយាយបាន។ ខ្លួនអាចអានសំណួរដែលតំណាងអយ្យការសរសេរដាក់ក្រដាស់បាន និងអាចឆ្លើយទៅតាមសំណួរវិញបាន។ ខ្លួនមិនចង់បានមេធាវីឡើយ ដោយសារតែខ្លួនគ្មានប្រាក់ជួលមេធាវី ហើយខ្លួនឱ្យកូនប្រសារខ្លួនឈ្មោះ [redacted] ផន ជាអ្នកដឹងរឿងវិវាទដីនេះជាអ្នកតំណាងឱ្យខ្លួនក្នុងការប្តឹងផ្តល់។ ខ្លួនពិតជាជនរងគ្រោះក្នុងសំណុំរឿងខាងលើពិតប្រាកដមែនដោយសារតែខ្លួនមានវ័យចាស់ជរា ភ្លេចភ្លាំងច្រើនមិនសូវចាំអ្វីច្រើន និងមានជំងឺត្រចៀកមិនអាចស្តាប់បានទៀត ដូច្នេះហើយទើបបានជាខ្លួនឱ្យកូនប្រសារខ្លួនឈ្មោះ [redacted] ផន ភេទប្រុស អាយុ៦៤ឆ្នាំ ធ្វើជាដើមបណ្តឹងជំនួសខ្លួនក្នុងសំណុំរឿងនេះ។ កន្លងមកខ្លួនពិតជាបានផ្ទេរសិទ្ធិឱ្យកូនប្រសារខ្លួនឈ្មោះ [redacted] ផន ដាក់ពាក្យបណ្តឹងនានាលើរឿងវិវាទដីរបស់ខ្លួនឈ្នះក្តីចំនួន២កន្លែង គឺដីលំនៅដ្ឋានចំនួន១កន្លែង និងដីស្រែចំនួន១កន្លែង និងដីស្រែចំនួន១កន្លែង ដែលស្ថិតនៅភូមិស្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ពិតប្រាកដមែន។ ខ្លួនស្នើសុំឱ្យតំណាងអយ្យការអនុញ្ញាឱ្យកូនប្រសារខ្លួនឈ្មោះ [redacted] ផន ឆ្លើយបំភ្លឺនូវដំណើររឿងទាំងអស់ និងធ្វើជាដើមបណ្តឹងក្នុងសំណុំរឿងខាងលើពីពេលនេះតទៅ ហើយខ្លួនសំណូមពរឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផងព្រមទាំងផ្តន្ទាទោសជនល្មើសតាមច្បាប់។

២-ដើមបណ្តឹងឈ្មោះ [redacted] ផន បានឆ្លើយថា៖ ខ្លួនត្រូវជាកូនប្រសាររបស់ឈ្មោះ [redacted] សាមិត្ត ដោយសារតែម្តាយក្មេកខ្លួនបច្ចុប្បន្នមានជម្ងឺត្រចៀកទាំងសងខាង ដោយមិនអាចស្តាប់ឮបានទាំងស្រុងហើយគាត់មានវ័យចាស់ជរាភ្លេចភ្លាំងច្រើន ទើបបានជាគាត់ផ្ទេរសិទ្ធិឱ្យ ខ្លួនធ្វើជាដើមបណ្តឹងជំនួសគាត់ក្នុងរឿងក្តីនេះ។ ចំពោះពាក្យបណ្តឹងដែលខ្លួនបានប្តឹងលើឈ្មោះ [redacted] ហ៊ុន, ឈ្មោះ [redacted] សុផា, ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] ស្រីរ៉ាស់ ពាក់ព័ន្ធនឹងករណី ហិង្សាទៅលើអ្នកកាន់កាប់ អចលនវត្ថុដោយសុចរិតនោះគឺដោយមូលហេតុថាតុលាការខេត្តកំពង់ឆ្នាំង ចេញដីកាសម្រេចអំពីរឿងក្តីរដ្ឋប្បវេណី មិនមែនជាបណ្តឹងលេខ ០៤/១៨ ដោយសម្រេចឱ្យម្តាយក្មេកខ្លួនឈ្មោះ [redacted] សាមិត្ត ឈ្នះក្តីក្នុងវិវាទដី ដូចមានឯកសារភ្ជាប់ក្នុងពាក្យបណ្តឹងរួចហើយ តែភាគីជនសង្ស័យឈ្មោះ [redacted] ហ៊ុន, ឈ្មោះ [redacted] សុផា, ឈ្មោះ [redacted] សុផល, និងឈ្មោះ [redacted] ស្រីរ៉ាស់ នៅមិនព្រមចាកចេញពីដីរបស់ម្តាយក្មេកខ្លួនឡើយ ទើបបាន ជាម្តាយក្មេកខ្លួនប្តឹងឱ្យជនសង្ស័យទាំងអស់ចេញពីដីខាងលើនេះ។ សូមបញ្ជាក់បន្ថែមថាកាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ មេភូមិឈ្មោះ [redacted] សុទ្ធ បានមកហៅខ្លួនដល់ផ្ទះថា មេឃុំពង្រ ឱ្យទៅជួបនៅសាលាឃុំ លុះម៉ោង ១៣ ថ្ងៃត្រង់ ខ្លួនរង់ចាំរហូតដល់ម៉ោង ១៥ថ្ងៃត្រង់ ថ្ងៃខែឆ្នាំដដែល ក៏ឃើញឈ្មោះ [redacted] ឧត្តម នឹងឈ្មោះ [redacted] ចន្ថា ជាមេធាវីបានបើករថយន្តទៅដល់សាលាឃុំរួចភ្លាមនោះឈ្មោះ [redacted] ចន្ថា បានហៅខ្លួន ចូលទៅក្នុងបន្ទប់លោកមេឃុំពង្រ រួចបិទទ្វារដាក់គន្លឹះ ហើយឈ្មោះ [redacted] ឧត្តម បាននិយាយមកខ្លួនថា មាន ដឹងថាឯកសារផ្ទេរសិទ្ធិពីម្តាយក្មេកមកឱ្យខ្លួនក្នុងការដាក់បញ្ហាំងមកស្នងការនឹងខុសឬអត់? ហើយខ្លួនក៏ឆ្លើយ ថាអត់ដឹងដែរគឺមេឃុំជួយធ្វើឱ្យខ្លួន។ ពេលនោះឈ្មោះ [redacted] ឧត្តម បាននិយាយថាបើមិនចង់មានរឿងឱ្យខ្លួន ដកពាក្យបណ្តឹងនៅស្នងការខេត្ត, កងរាជអាវុធហត្ថខេត្ត និងនៅតុលាការទៅលែងមានរឿងហើយ។ ពេលនោះខ្លួនក៏ឆ្លើយថា ខ្លួនមិនដឹងទេទៅលើតែតុលាការចាត់ចែង ហើយពេលនោះឈ្មោះ [redacted] ចន្ថា បានទាញ កុំព្យូទ័រវាយឯកសារដកពាក្យបណ្តឹងឱ្យខ្លួនផ្តិតមេដៃ ដោយពេលនោះឈ្មោះ [redacted] ឧត្តម បាននិយាយថា លោកមេឃុំ និងលោកមេភូមិបានធ្វើលិខិតមោឃៈភាពឯកសារកន្លងមកអស់ហើយ

ដូច្នេះឱ្យខ្លួនត្រូវតែផ្តិត មេដៃដកពាក្យបណ្តឹងដូចគ្នាទៅ។ ពេលនោះខ្លួនមានការភ័យខ្លាចចេះតែផ្តិតមេដៃតាមគេទៅ។ លុះក្រោយ មកថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ ខ្លួនក៏បានដាក់ពាក្យបណ្តឹងមកអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង រួចហើយ ដោយពាក្យបណ្តឹងនោះចូលទៅលោក កែវ វ៉ាន្នី ជាតំណាងអយ្យការទទួលដោះស្រាយរឿងបញ្ចាំង ឱ្យខ្លួន។ ដោយក្នុងបណ្តឹងនោះខ្លួនបានប្តឹងលើឈ្មោះ [redacted]ឧត្តម, ឈ្មោះ [redacted] ចន្ថា, ឈ្មោះ [redacted]ស្រីវ៉ាស, ឈ្មោះ [redacted] ហ៊ុន, និងឈ្មោះ [redacted] ម សុផា រួចហើយ។ ខ្លួនសំណូមពរដល់តំណាងអយ្យការជួយរកយុត្តិធម៌ ដល់ខ្លួនផង និងសុំឱ្យជនសង្ស័យខាងលើ ចេញពីដីម្តាយក្មេកខ្លួនវិញ។ ក្នុងរឿងនេះខ្លួនប្តឹងសុំទាមទារសំណងជំងឺចិត្តចំនួន ៥,០០០(ប្រាំពាន់)ដុល្លារអាមេរិក។

៣-ជនជាប់ចោទឈ្មោះ [redacted] ហ៊ីន បានឆ្លើយថា៖កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ខ្លួនបានទិញដីចំនួន ១ កន្លែង មានទំហំទទឹង ៧ម៉ែត្រ x បណ្តោយ ៣៦ម៉ែត្រ ស្ថិតនៅចំណុចភូមិស្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដោយដីនេះខ្លួន និងប្រពន្ធ ខ្លួនបានទិញពីឈ្មោះ[redacted] សុផល ក្នុងតម្លៃ ២,០០០USD (ពីរពាន់ដុល្លារអាមេរិក) មុនពេលខ្លួន និងប្រពន្ធ ទៅទិញដីនេះខ្លួនបានទៅសួរមេភូមិឈ្មោះ [redacted] សុទ្ធ និងមេឃុំឈ្មោះ [redacted] សុផល ថាដីនេះមានបញ្ហាឬអត់ហើយពួកគាត់ ថាមិនមានបញ្ហាអ្វីឡើយ ដោយគាត់បានចុះហត្ថលេខាលើលិខិតទិញលក់ត្រឹមត្រូវពេលទិញ រួចហើយខ្លួននិងប្រពន្ធបានសង់ខ្ទមរស់នៅរហូតដល់បច្ចុប្បន្ន។ ទើបនៅក្នុងអំឡុងឆ្នាំ២០១៨ មានខាង សុរិយោដីខេត្តចុះមកវាស់វែងធ្វើប្លង់ ពេលនោះខ្លួនបានទៅសួរអាជ្ញាធរភូមិឃុំ ថាហេតុអ្វីគេមិនវាស់វែងដីឱ្យ ខ្លួនពេលនោះអាជ្ញាធរឆ្លើយថារឿងនេះគាត់នឹងពិភាក្សាគ្នាជាមួយខាងសុរិយោដីខេត្តសិន ក្រោយមកខ្លួនបាន ទៅជួបសុរិយោដីគេក៏បានហៅខ្លួនហៅឈ្មោះ[redacted]សុផល និងឈ្មោះ[redacted]សាមិត្ត ដើម្បីទៅសម្រុះសម្រួល ពេលនោះឈ្មោះ [redacted]សាមិត្ត បានព្រមព្រៀងប្រគល់ដីខាងលើទំហំ ៧ម៉ែត្រ x ៣៦ម៉ែត្រ មកឱ្យខ្លួនហើយតែ ឈ្មោះ [redacted] សុផល មិនឯកភាពក៏ការសម្របសម្រួលនេះមិនបានលទ្ធផល។ ពេលខ្លួនទិញដីនេះដំបូងខ្លួនមិន ដឹងថាឈ្មោះ [redacted] សុផល យកដីជាទ្រព្យរបស់ប្រពន្ធគាត់ដែលពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ ជាមួយគ្នាតាមច្បាប់មកលក់ឱ្យខ្លួនឡើយ បើសិនជាខ្លួនដឹងក៏ខ្លួនមិនទិញដីខាងលើនេះដែរ។ ចំពោះដី និងខ្ទមដែលខ្លួន កំពុងរស់នៅជាមួយប្រពន្ធកូននេះគឺខ្លួនមិនអាចចុះទៅរស់នៅទីណាផ្សេងបានឡើយព្រោះខ្លួនមានតែដី និងខ្ទមមួយនេះសម្រាប់រស់នៅតែប៉ុណ្ណោះដោយពុំមានកន្លែងរស់នៅផ្សេងទៀតឡើយ។ ក្នុងរឿងខាងលើ នេះខ្លួនពុំបានប្តឹងឈ្មោះ [redacted] សុផល នោះទេដោយឃើញពីស្ថានភាពគ្រួសារ របស់ឈ្មោះ [redacted] សុផល មានការ លំបាក រីឯឈ្មោះ [redacted] សុផល កំពុងជាប់ពន្ធនាគារពាក់ព័ន្ធនឹងដីវិវាទខាងលើនេះទៀត។ ក្នុងរឿងនេះខ្លួនសុខចិត្ត ចាកចេញពីដីខាងលើឱ្យបានមុន ថ្ងៃប្រកាសសាលក្រម គឺថ្ងៃទី០២ ខែមេសា ឆ្នាំ២០២៤។

៤-ជនជាប់ចោទឈ្មោះ [redacted] សុផា បានឆ្លើយថា៖កាលពីអំឡុងឆ្នាំ២០១៥ ខ្លួន និងប្តីឈ្មោះ ញ៉ែម ហ៊ុន បាននាំគ្នាមកជួលដីរបស់ឈ្មោះ [redacted]សុផល ដើម្បីធ្វើ ផ្ទះរស់នៅបណ្តោះអាសន្ន ដោយជួលក្នុងរយៈពេល១ឆ្នាំពេញ ដែលមានតម្លៃចំនួន ២៤០,០០០៛ (ម្ភៃបួន ម៉ឺនរៀល) ដែលដីខាងលើស្ថិតនៅភូមិស្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដោយមានវត្តមាន ឈ្មោះ [redacted]សុផល និងប្រពន្ធឈ្មោះ [redacted] សាមៀន រស់នៅជិតពួកខ្លួនដែរ បន្តរហូតដល់ឆ្នាំ២០១៧ រូបខ្លួន និងប្តីចាប់ផ្តើមពិភាក្សាដោយចង់ទិញដីនៅចំណុចខាងលើ ពេលដែលសួរនាំឈ្មោះ [redacted] សុផល ក៏បានព្រម ព្រៀងលក់ឱ្យរូបខ្លួននិងប្តីដោយដីទំហំទទឹង ៧ម៉ែត្រ និងបណ្តោយ ៣៧ម៉ែត្រ ក្នុងតម្លៃ ១០,០០០,០០០៛ (ដប់លានរៀល) អំឡុងពេលដែលលក់ដីឈ្មោះ[redacted]សុផល ព្រមព្រៀងលក់តែម្នាក់ឯងទេ គឺប្រពន្ធឈ្មោះ [redacted]សាមៀន បានស្លាប់ហើយ ក្នុងការទិញដីរបស់ឈ្មោះ



Scanned with CamScanner

[redacted]សុផល រូបខ្លួន និងប្ដីគឺធ្វើឯកសារត្រឹមភូមិឃុំទេ ដោយមានមេភូមិឈ្មោះ [redacted] សុទ្ធ និងមេឃុំឈ្មោះ [redacted] សុផល ជាអ្នកចុះហត្ថលេខា លើឯកសារដី រូបខ្លួន និងប្ដីទទួលស្គាល់ថាពិតជាបានទិញដីពីឈ្មោះ [redacted] សុផល ពិតប្រាកដមែន និងបានរស់នៅលើដីដោយ ធ្វើរោងសម្រាប់រស់នៅបណ្ដោះអាសន្ន រហូតដល់បច្ចុប្បន្នពិតប្រាកដមែន។ ក្នុងរឿងនេះខ្លួនសុខចិត្ត ចាកចេញពីដីខាងលើឱ្យបានមុន ថ្ងៃប្រកាសសាលក្រម គឺថ្ងៃទី០២ ខែមេសា ឆ្នាំ២០២៤។

៥-សាក្សីឈ្មោះ [redacted] សុផល បានឆ្លើយថា៖ ខ្លួនជាមេឃុំពង្រ ចំពោះសំណុំរឿង ដែលមានដើមបណ្ដឹងឈ្មោះ [redacted] ផន បានប្ដឹងលើឈ្មោះ [redacted] ហ៊ិន, ឈ្មោះ [redacted] សុផា, ឈ្មោះ [redacted] សុផល, និងឈ្មោះ [redacted] ស្រីវ៉ាស់ ពាក់ព័ន្ធនឹងករណី ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត គឺខ្លួនដឹង រឿងខ្លះដែរ ចំពោះប្រវត្តិវិវាទដីលំនៅដ្ឋានចំនួន ១កន្លែង និងដីស្រែ ១កន្លែង (មិនចាំទំហំ) ស្ថិតនៅភូមិក្រាំង ខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីដំបូងឡើយគឺជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] សាមៀន និង ប្ដីឈ្មោះ [redacted] សារឿន លុះក្រោយមកទៀតមិនចាំថ្ងៃខែឆ្នាំឈ្មោះ [redacted] សារឿន ក៏បានស្លាប់បាត់ រីឯឈ្មោះ [redacted] សាមៀន បានយកប្ដីថ្មីទៀតឈ្មោះ [redacted] សុផល តែពុំបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងតាមច្បាប់ ឡើយ។ លុះក្រោយមកនៅឆ្នាំ២០១៤ ឈ្មោះ [redacted] សាមៀន បានស្លាប់ទៀតដោយពុំមានកូនឡើយ។ ក្រោយការស្លាប់របស់អ្នកទាំងពីរខាងលើ បានបន្សល់ដីលំនៅដ្ឋានចំនួន ១កន្លែង និងដីស្រែ ១ កន្លែង (មិនចាំទំហំ) ស្ថិតនៅភូមិក្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ លុះនៅថ្ងៃខែឆ្នាំមិនចាំពេល វេសៀល មានប្រជាពលរដ្ឋជាអ្នកទិញមានឈ្មោះ [redacted] សុផា បានមកដល់ផ្ទះខ្លួនដោយកាន់លិខិតទិញលក់ ដីលំនៅដ្ឋានមួយចំណែកជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] សាមៀន (ស្លាប់) ដោយឃើញឈ្មោះ [redacted] សុផល (ត្រូវ ជាប្ដីឈ្មោះ [redacted] សាមៀន) ដាក់ឈ្មោះជាភាគីអ្នកលក់ រីឯអ្នកទិញមានឈ្មោះ [redacted] ហ៊ិន និងប្រពន្ធឈ្មោះ [redacted] សុផា ពេលនោះខ្លួនឃើញមានចុះហត្ថលេខាពីមេភូមិ ចុះលេខស្មៀនឃុំ និងវាយត្រារួចស្រេច ខ្លួនទុក ចិត្តក៏ចុះហត្ថលេខាឱ្យគាត់ទៅដោយមិនបានពិនិត្យឱ្យបានល្អិតល្អន់ឡើយ។ លុះក្រោយមកទៀតទើបដឹង ថាដីដែលខ្លួនចុះហត្ថលេខាលក់ទិញរវាងឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] ហ៊ិន ព្រមទាំងប្រពន្ធឈ្មោះ [redacted] សុផា នោះមិនត្រឹមត្រូវទេ ហើយខ្លួនក៏បានចេញលិខិតមោឃៈភាពលើលិខិតទិញលក់នោះ រួចមាន ភាគីប្ដឹងផ្ដល់គ្នាដល់តុលាការ ហើយតុលាការក៏បានសម្រេចឱ្យឈ្មោះ [redacted] សាមិត្ត (ត្រូវជាបងបង្កើតរបស់ ឈ្មោះ [redacted] សាមៀន) ឈ្នះក្ដីបានដីលំនៅដ្ឋាន និងដីស្រែចំនួន ១កន្លែងទៀត ពោលគឺឈ្មោះ [redacted] សុផល បានចាញ់ក្ដីក្នុងរឿងទិញលក់ដីលំនៅដ្ឋាននេះ។ ក្រោយមកទៀតនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣ តំណាងអយ្យការបានហៅខ្លួនមកសាកសួរពីដំណើរដើមបណ្ដឹងឈ្មោះ [redacted] ផន បានប្ដឹងលើឈ្មោះ [redacted] ហ៊ិន, ឈ្មោះ [redacted] សុផា, ឈ្មោះ [redacted] សុផល, និងឈ្មោះ [redacted] ស្រីវ៉ាស់ ពាក់ព័ន្ធនឹងករណី ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុ ដោយសុចរិត ចំពោះករណីនេះខ្លួនក៏មិនបានដឹងច្បាស់ថាឈ្មោះ [redacted] ហ៊ិន, ឈ្មោះ [redacted] សុផា និងឈ្មោះ [redacted] ស្រីវ៉ាស់ រស់នៅលើដីដែលធ្លាប់មានវិវាទប្ដឹងផ្ដល់គ្នាទៀត ឬក៏អត់ឡើយ។ ប៉ុន្តែកាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ៨ ព្រឹក ស្រាប់តែមានឈ្មោះ [redacted] ឧត្ដម ភេទប្រុស អាយុមិនដឹង មុខរបរជាអ្នកសារ ព័ត៌មាន មានទីលំនៅស្នាក់នៅភូមិមិនស្គាល់ សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង និងឈ្មោះ [redacted] ចន្ថា ភេទប្រុស អាយុមិនដឹង ជាមេធាវីក្នុងសំណុំរឿងនេះ បានចូលមកដល់បន្ទប់ធ្វើការរបស់ខ្លួននៅសាលាឃុំ ពង្រ ដោយសួរខ្លួនថារឿងឈ្មោះ [redacted] សុផល ដែលជាប់ពន្ធនាគារដោយសារការផ្ទេរសិទ្ធិរវាងឈ្មោះ [redacted] សាមិត្ត ទៅឱ្យឈ្មោះ [redacted] ផន ដោះស្រាយវិវាទនៅតុលាការនោះតើពូដឹងរឿងទេ? ហើយខ្លួនឆ្លើយថាខ្លួន មិនដឹងទេ ពេលនោះឈ្មោះ [redacted] ឧត្ដម បាននិយាយថាគាត់អាណិតឈ្មោះ [redacted] សុផល ដែល



Scanned with CamScanner

ជាប់ពន្ធនាគារ ដោយសូមឱ្យឈ្មោះ [redacted] ផន ដកពាក្យបណ្ដឹងមកវិញ ពេលនោះឈ្មោះ [redacted] ឧត្តម បានឱ្យខ្លួនអញ្ជើញមេភូមិ ឈ្មោះ [redacted] សុទ្ធ និងឈ្មោះ [redacted] ផន មកជួបគ្នានៅសាលាឃុំពង្រ នៅថ្ងៃខែឆ្នាំដដែលវេលាម៉ោង ២រសៀល លុះម៉ោងប្រហែលជា៣រសៀល ទើបឈ្មោះ [redacted] ឧត្តម និងឈ្មោះ [redacted] ចន្ថា មកដល់ហើយបាននាំគ្នាចូល បន្ទប់របស់ខ្លួន ដោយឈ្មោះ [redacted] ចន្ថា ដើរទៅហៅឈ្មោះ [redacted] ផន ឱ្យចូលមកក្នុងបន្ទប់ខ្លួន រួចហើយឈ្មោះ [redacted] ឧត្តម បានសួរទៅឈ្មោះ [redacted] ផន ថា តើលិខិតផ្ទេរសិទ្ធិលើពាក្យបណ្ដឹងពីឈ្មោះ [redacted] សាមិត្ត មកឱ្យ លោកនោះតើនរណាជាអ្នកធ្វើ? ពេលនោះ ឈ្មោះ [redacted] ផន បានឆ្លើយថាខ្លួនបានយកពីតុលាការ។ មួយ សន្ទុះក្រោយមកមេភូមិឈ្មោះ [redacted] សុទ្ធ បានអញ្ជើញមកដល់បន្ទប់ដែរ ភ្លាមនោះឈ្មោះ [redacted] ឧត្តម ក៏និយាយ ថាបើលោកមេឃុំ និងលោកមេភូមិ មិនចង់មានការពាក់ព័ន្ធពីរឿងនឹងទេ សូមឱ្យមោឃភាពលិខិតទាំងអស់ ដែលភូមិឃុំបានធ្វើដាក់ជូនទៅតុលាការកន្លងទៅដែលពាក់ព័ន្ធនឹងរឿងឈ្មោះ [redacted] សុផល ពេលនោះខ្លួនមិន បានគិតវែងឆ្ងាយដោយភ័យខ្លាចឈ្មោះ [redacted] ឧត្តម ផ្សព្វផ្សាយព័ត៌មានពីខ្លួនទៀត ដូច្នេះក៏បានយល់ព្រមចុះហត្ថលេខាលើលិខិតបញ្ជាក់លេខ៤៦៦/០២៣ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ និងលិខិតលេខ ៤៦៥/ ០២៣ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ ព្រមទាំងលិខិតជូនដំណឹងគ្មានលេខចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ ទាំងពុំបានពិនិត្យអំពីខ្លឹមសារនៃលិខិតនោះឡើយ ចំពោះលិខិតនេះឈ្មោះ [redacted] ចន្ថា ជាអ្នកតាក់តែងវាយ ចូលក្នុងកុំព្យូទ័ររួចព្រីននៅបន្ទប់ស្មៀនឃុំ។ និយាយជារួមលិខិតដែលខ្លួនចុះហត្ថលេខាខាងលើនោះគឺ ឈ្មោះ [redacted] ឧត្តម និងឈ្មោះ [redacted] ចន្ថា ជាអ្នករៀបចំរួចជាស្រេច ហើយដើម្បីទុកឱ្យខ្លួនចុះហត្ថលេខា។ នៅ ថ្ងៃនោះខ្លួនក៏ឃើញឈ្មោះ [redacted] ផន បានផ្ដិតមេដៃលើឯកសារដកពាក្យបណ្ដឹងនៅតុលាការវិញដែរ តែខ្លួន មិនបានថតចម្លងលិខិតនោះឡើយ។ លុះនៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ខ្លួនក៏ពិនិត្យមើលលិខិតដែល ឈ្មោះ [redacted] ឧត្តម និងឈ្មោះ [redacted] ចន្ថា បង្ខំឱ្យខ្លួនចុះហត្ថលេខាដោយយកមកមើលក៏ឃើញក្នុងខ្លឹមសារថា ខ្លួនជាមេឃុំមោឃៈលិខិតបញ្ជាក់នានាដែលបានធ្វើដាក់ជូនតុលាការកន្លងមកចោលទាំងអស់។ ភ្លាមនោះ ទើបខ្លួនដឹងថាឈ្មោះ [redacted] ឧត្តម និងឈ្មោះ [redacted] ចន្ថា ប្រើល្បិចបោកបញ្ឆោតខ្លួនឱ្យចុះហត្ថលេខាខុសច្បាប់ បែបនេះ ខ្លួនក៏សម្រេចភ្លាមៗដាក់លិខិតមោឃៈភាពជូនទៅ ៣ស្ថាប័ន គឺតុលាការខេត្ត, ស្នងការខេត្ត, និង អាវុធហត្ថខេត្ត ដើម្បីសុំមោឃៈភាពលើលិខិតទាំងអស់ដែលឈ្មោះ [redacted] ឧត្តម និងឈ្មោះ [redacted] ចន្ថា បាន បង្ខិតបង្ខំ និងប្រើល្បិចកលបោកបញ្ឆោតឱ្យខ្លួនចុះហត្ថលេខាកាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ វិញ ទាំងអស់ ហើយក្នុងរឿងឈ្មោះ [redacted] ឧត្តម និងឈ្មោះ [redacted] ចន្ថា បង្ខិតបង្ខំឱ្យខ្លួនចុះហត្ថលេខានោះគឺមាន សាក្សីឈ្មោះ [redacted] ផន និងមេភូមិឈ្មោះ [redacted] សុទ្ធ ក៏បានដឹងរឿងនេះដែរ ខ្លួនចាំតែប៉ុណ្ណឹង។

៦.សាក្សីឈ្មោះ [redacted] សុទ្ធ បានឆ្លើយថា ៖ ខ្លួនជាមេភូមិក្រាំងខ្ពស់តាំងពីឆ្នាំ ២០០៦ មកម្ល៉េះ។ ចំពោះសំណុំរឿងដែលមានដើមបណ្ដឹងឈ្មោះ [redacted] ផន បានប្ដឹងលើឈ្មោះ [redacted] ហ៊ុន, ឈ្មោះ [redacted] សុផា, ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] ស្រីវាស់ ពាក់ព័ន្ធនឹងករណី ហិង្សាទៅលើអ្នកកាន់ កាប់អចលនវត្ថុដោយសុចរិត គឺខ្លួនដឹងរឿងខ្លះដែរ បច្ចុប្បន្ននេះក្រោយឈ្មោះ [redacted] សាមិត្ត បានឈ្នះក្ដីរឿង វិវាទដីលំនៅដ្ឋានស្ថិតនៅភូមិក្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ឈ្មោះ [redacted] សាមិត្ត មិនទាន់ បានចូលទៅគ្រប់គ្រងដីដែលគាត់ឈ្នះក្ដីឡើយ ដោយខ្លួនជាមេភូមិបានឃើញឈ្មោះ [redacted] ហ៊ុន, ឈ្មោះ [redacted] សុផា, និងឈ្មោះ [redacted] ស្រីវ៉ាស់ ដែលចាញ់ក្ដីកំពុងរស់នៅលើដីនេះដដែល ដោយឡែកឈ្មោះ [redacted] សុផល កំពុងជាប់ពន្ធនាគារនៅខេត្តកំពង់ឆ្នាំង។ ចំពោះលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ របស់ ឈ្មោះ [redacted] សាមិត្ត ផ្ទេរសិទ្ធិជូនឈ្មោះ [redacted] ផន ដោះស្រាយរឿងក្ដីនៅតុលាការនោះ គឺខ្លួនមិនបានចូលរួម ចុះហត្ថលេខាបញ្ជាក់ឡើយ គឺមានតែហត្ថ

លេខារបស់លោកមេឃុំពងឈ្មោះ [redacted] សុផល តែប៉ុណ្ណោះ។ ដោយឡែកកាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ៨ព្រឹក លោកមេឃុំឈ្មោះ [redacted] សុផល បាន ហៅខ្លួនឱ្យទៅសាលាឃុំ។ លុះពេលទៅដល់ខ្លួនឃើញឈ្មោះ [redacted] ឧត្តម និង មនុស្សម្នាក់ទៀត ភេទប្រុស មិនស្គាល់ឈ្មោះនៅទីនោះហើយភ្លាមៗនោះឈ្មោះ [redacted] ឧត្តម បាននិយាយដាក់គំនៀបមកខ្លួន ថា "មេភូមិ មេឃុំចេះតែចុះហត្ថលេខាឱ្យមនុស្សជាប់គុកបាន" ហើយឈ្មោះ [redacted] ឧត្តម បានលួងលោមខ្លួនទៀតថា "ឱ្យខ្លួន និងលោកមេឃុំចុះហត្ថលេខាមោឃៈភាពលើលិខិតផ្ទេរសិទ្ធិប្តឹងផ្តល់រវាងឈ្មោះ [redacted] សាមិត្ត និង ឈ្មោះ [redacted] ជន ដើម្បីដោះលែងឈ្មោះ [redacted] សុផល ចេញពីពន្ធនាគារវិញ ពេលនោះខ្លួនក៏ឯកភាពតាម រីឯ លិខិតដែលត្រូវធ្វើឱ្យខ្លួន និងលោក មេឃុំចុះហត្ថលេខានោះគឺគ្នារបស់ឈ្មោះ [redacted] ឧត្តម ម្នាក់ទៀតភេទ ប្រុស មិនស្គាល់ឈ្មោះ ជាអ្នកគាក់តែងលិខិតនោះឡើង។ លុះក្រោយពេលចុះហត្ថលេខារួច ខ្លួនបានស្តាប់ឈ្មោះ [redacted] ឧត្តម អានខ្លឹមសារលិខិតនោះដែរ តែមិនចាប់អារម្មណ៍ រឿងគេអានត្រង់ចំណុចមោឃភាពលិខិតផ្សេងៗ ដែលខ្លួន និងមេឃុំធ្លាប់បានធ្វើទៅតុលាការកន្លងមកឡើយ។ លុះបាន ប្រហែលជា ៣ថ្ងៃ ក្រោយចុះហត្ថ លេខាលើលិខិតខាងលើនេះរួច ទើបលោកមេឃុំឈ្មោះ [redacted] សុផល បានយកលិខិតនោះ មកអានឡើងវិញ ទើបដឹងថាឈ្មោះ [redacted] ឧត្តម និងបក្ខពួកគេធ្វើលិខិតឱ្យខ្លួន និងលោកមេឃុំចុះហត្ថលេខានោះគឺជាលិខិត មោឃៈភាពចោលនូវលិខិតដែលខ្លួន និងលោកមេឃុំធ្លាប់បានធ្វើកន្លងមកសម្រាប់ដាក់ទៅតុលាការទាំងអស់ ដូច្នេះទើបបាន ជាថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ខ្លួន និងលោកមេឃុំក៏បានធ្វើលិខិតមោឃៈភាពរាល់លិខិត ធ្វើជាមួយឈ្មោះ [redacted] ឧត្តម និង បក្ខពួក នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ ចោលទាំងអស់វិញ រួចមេឃុំ បានដាក់លិខិតនោះទៅតាមស្ថាប័នពាក់ព័ន្ធផ្សេងៗ ទៀតដើម្បីទុកជាការជូនដំណឹង។

៧.សាក្សីឈ្មោះ [redacted] ស្រីហ្វាស់ បានឆ្លើយថា ៖ខ្លួនត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] សុផល ដោយខ្លួនបានសែនជាមួយ គ្នាតាំងពីឆ្នាំ២០១៧ នៅប្រទេសថៃ ដោយមិនបានចុះសំបុត្រអាពាហ៍ ពិពាហ៍ឡើយ។ លុះឆ្នាំ២០១៨ ខ្លួនបានមកពីប្រទេស ថៃម្នាក់ឯងមករស់នៅផ្ទះជាមួយម្តាយក្មេកខាងប្តីស្ថិត នៅភ្នំតាសាំ ដោយមិនបានរស់នៅលើដីកំពុងមានវិវាទនេះទេ។ លុះ នៅឆ្នាំ២០១៩ ប្តីខ្លួនបានហៅទៅរស់ នៅលើដីវិវាទនោះ ដោយខ្លួនឃើញមានផ្ទះថ្មដែលប្តីខ្លួនបានសាងសង់តាំងពីប្រពន្ធដើម គាត់ឈ្មោះ ផ្លុង សាមៀន នៅមានជីវិតម្ល៉េះ។ ពេលខ្លួនទៅរស់នៅទីនោះគឺពុំដឹងថាដីខាងលើនេះមានវិវាទឡើយ។ ចំពោះ វិវាទដីខាងលើនេះ កន្លងមកមានបញ្ហាវិវាទជាមួយនរណាខ្លះនោះគឺខ្លួនពុំដឹងឡើយព្រោះខ្លួនជាប្រពន្ធក្រោយ របស់ប្តីឈ្មោះ ចិ សុផល។ រីឯការទិញលក់ដីខាងលើនេះក៏មិនពាក់ព័ន្ធនឹងខ្លួនដែរ ព្រោះកន្លងមកបញ្ហាលើ ដីវិវាទនេះ គឺប្តីខ្លួនគាត់ដឹង ច្បាស់រីឯខ្លួនពុំសូវដឹងរឿងអ្វីឡើយ។ បច្ចុប្បន្នខ្លួនពុំបានរស់នៅលើដីនេះទៀតទេ។

៨.តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សុផល បានឆ្លើយថា៖ កន្លងមកខ្លួន និងឈ្មោះ [redacted] សាមៀន បានរួម រស់នៅជាមួយគ្នាតាំងពីឆ្នាំ១៩៩៤ មកម្ល៉េះ ដោយគាត់បានយកខ្លួនមកចិញ្ចឹមធ្វើជាកូន ធម៌ពិតមែន ក្រោយមកឈ្មោះ [redacted] សាមៀន បានរៀបចំអាពាហ៍ពិពាហ៍ខ្លួនជាមួយនឹងលោកស្រី [redacted] សាម៉េត ពិតមែន ដោយខ្លួនមិនចាំថ្ងៃខែឆ្នាំនោះទេ។ ក្រោយមកទៀតក៏បានលែងលះគ្នាហើយខ្លួនក៏មកសុំ រួមរស់ជាមួយលោកស្រី [redacted] សាមៀន វិញ ដោយមិនបានរៀប អាពាហ៍ពិពាហ៍ទេ ប៉ុន្តែខ្លួនបានសែនជាមួយគ្នារហូតមកដល់ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៤ ឈ្មោះ ផ្លុង សាមៀន ក៏ត្រូវបាន ទទួលមរណៈភាព បងប្អូនបង្កើតរបស់ឈ្មោះ [redacted] សាមៀន មានគ្នាចំនួន ៣នាក់មានឈ្មោះ [redacted] សាមិត្ត ត្រូវជាបងគេ, ឈ្មោះ [redacted] សាមៀន និងម្នាក់ទៀតមិនចាំឈ្មោះ ហើយបងប្អូនបង្កើតរបស់គាត់នេះស្លាប់ ២នាក់ហើយ គឺនៅតែ ឈ្មោះ [redacted]



Scanned with CamScanner

សាមិត្ត ទេដែលរស់នៅបច្ចុប្បន្ននេះ។ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ខ្លួនពិតជាយកដីរបស់ ឈ្មោះ [redacted] សាមឿន ត្រូវជាប្អូនរបស់ឈ្មោះ [redacted] សាមិត្ត លក់ទៅឱ្យឈ្មោះ [redacted] សុផា ហៅ មុំ ភេទស្រី និង ឈ្មោះ [redacted] ហ៊ុន ហៅ គ្រុយ (ប្តីប្រពន្ធ) ដែលមានទទឹង ៧ម៉ែត្រ និងបណ្តោយ ៣៥ម៉ែត្រ ពិតមែន នៅ ចំណុចភូមិក្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ក្នុងតម្លៃ ២,000USD (ពីរពាន់ដុល្លារអាមេរិក) ចំណែកប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] ស្រីហ្វាស់ គាត់មិនបានលក់ដីនោះទៅឱ្យឈ្មោះ [redacted] សុផា ហៅ មុំ ភេទស្រី និងឈ្មោះ [redacted] ហ៊ុន ហៅ គ្រុយ (ប្តីប្រពន្ធ) នោះទេ។ ខ្លួនមិនយល់អំពីផ្លូវច្បាប់ បានលក់ដីនោះ ដែលមិនមែនជារបស់ខ្លួនទៅឱ្យអ្នកដទៃ គឺខ្លួនសូមឱ្យតំណាងអយ្យការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួនផង បើសិនថ្ងៃក្រោយខ្លួនមិនកែប្រែទេខ្លួនសូមឱ្យតុលាការដាក់ទោសធ្ងន់ជាងនេះតទៅទៀត។

៩-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយរបស់សាក្សី និងកំណត់ហេតុនានានៅក្នុងសំណុំរឿង ពេលសវនាការរួចមកឃើញថា: កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្ថិតនៅភូមិក្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ឈ្មោះ [redacted] សុផល ពិតជាបានលួចលក់ដីដែល ជាកម្មសិទ្ធិរបស់ជនរងគ្រោះឈ្មោះ [redacted] សាមិត្ត លក់ទៅឱ្យទៅឈ្មោះ [redacted] ហ៊ុន ភេទប្រុស និងឈ្មោះ [redacted] សុផា អស់ទំហំ៧ ម៉ែត្រ និងបណ្តោយ ៣៥ម៉ែត្រ ក្រោយមកជនរងគ្រោះឈ្មោះ [redacted] សាមិត្ត ក៏បានដាក់ពាក្យប្តឹងលើឈ្មោះ [redacted] សុផល ហើយត្រូវបានតុលាការខេត្តកំពង់ឆ្នាំងសម្រេចផ្តន្ទាទោសតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ១២ "ខ" ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ដាក់ពន្ធនាគារកំណត់រយៈពេល ១ (មួយ) ឆ្នាំ ពីបទ លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន ដោយឡែកឈ្មោះ [redacted] ហ៊ុន និងប្រពន្ធឈ្មោះ [redacted] សុផា ដែលបានទិញ ដីពីឈ្មោះ [redacted] សុផល ក៏ត្រូវបានឈ្មោះ [redacted] សាមិត្ត ប្តឹងពីបទ កាប់បំផ្លាញដើមត្នោត និងដើមអំពិល នៅលើដីដែលបានទិញនោះអស់ចំនួន ០៤ ដើម រហូតដល់តុលាការខេត្តកំពង់ឆ្នាំងសម្រេចផ្តន្ទាទោសអ្នកទាំងពីរ ដាក់ពន្ធនាគារចំនួន ៦ (ប្រាំមួយ) ខែ ក្នុងម្នាក់ៗតែទោសនេះត្រូវអនុវត្តព្យួរធម្មតា ពីបទ ធ្វើឱ្យខូចខាត ដោយចេតនា ប្រព្រឹត្តនៅចំណុចភូមិស្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១២ ខែ ឧសភា ឆ្នាំ២០២១ តាមសាលក្រមព្រហ្មទណ្ឌលេខ ១៨៧ "ច" ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ តែទោះបីជា តុលាការបានសម្រេចសេចក្តីរួចហើយក៏ដោយក៏ឈ្មោះ [redacted] ហ៊ុន និងឈ្មោះ [redacted] សុផា នៅតែមិនចាកចេញ និងបានកាន់កាប់ដីលើទីតាំងដែលបានទិញដោយខុសច្បាប់នោះរហូតមកដល់សព្វថ្ងៃ ប្រាកដមែន។ ក្នុងករណីដែលជនជាប់ចោទព្រមចាកចេញពីដីទំនាស់ខាងលើដោយស្ម័គ្រចិត្ត តំណាងអយ្យការប្តឹងសុំឱ្យតុលាការសម្រេចឱ្យជនជាប់ចោទពីរនាក់រួចខ្លួនពីបទចោទ: ប៉ុន្តែបើជនជាប់ចោទមិនព្រមចាកចេញពីដីទំនាស់ខាងលើទេនោះ តំណាងអយ្យការប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទទាំងពីរឱ្យធ្ងន់ធ្ងរតាមច្បាប់ និងប្តឹងសុំឱ្យតុលាការចេញដីកាបង្គាប់ឱ្យចាប់ខ្លួន និងឃុំខ្លួន។

១០-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការរួចមកឃើញថា កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ កូនក្តីខ្លួនឈ្មោះ [redacted] ហ៊ុន និងប្រពន្ធឈ្មោះ [redacted] សុផា បានធ្វើលិខិតលក់ដីមួយកន្លែងនៅភូមិស្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ជាមួយឈ្មោះ [redacted] សុផល ក្នុងតម្លៃ២,000(ពីរពាន់)ដុល្លារអាមេរិក ស្របទៅតាមច្បាប់ គឺធ្វើជាលិខិតលក់ផ្តាច់ លេខ ៤០៨/០១៧ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ របស់សាលាឃុំពង្រ។ ប៉ុន្តែក្រោយមកទៀតក៏ដឹងថាឈ្មោះ [redacted] សុផល ពុំមែនជាម្ចាស់កម្មសិទ្ធិ



Scanned with CamScanner

លើដីលក់នោះទេ តាមពិតដីនេះជាដីរបស់ឈ្មោះ [redacted] សាមិត្ត ជាប្អូនរបស់ឈ្មោះ [redacted] សាមឿន ត្រូវជាអតីតប្រពន្ធឈ្មោះ ចិត សុផល។ ក្រោយមកទៀតកូនក្តីខ្លួនឈ្មោះ [redacted] ហ៊ីន និងប្រពន្ធឈ្មោះ [redacted] សុផា បានត្រូវឈ្មោះ [redacted] សាមិត ប្តឹងផ្តល់មិនចេះអស់មិនចេះហើយ ក្នុងគោលបំណងឱ្យកូនក្តីខ្លួនចេញពីដីដែលជាកម្មវត្ថុទិញលក់ខាងលើ។ គួរ បញ្ជាក់ដែរថា ពេលទិញលក់កូនក្តីខ្លួនពុំបានដឹងទេថាឈ្មោះ [redacted] សុផល ពុំមែនជាម្ចាស់ដី និងជឿជាក់យ៉ាងមុតមាំថាដីនេះជារបស់ឈ្មោះ [redacted] សុផល ព្រោះអាជ្ញាធរភូមិឃុំនៅទីនោះបានធ្វើលិខិតទិញលក់ដោយមានវាយត្រាចុះលេខត្រឹមត្រូវស្របទៅតាមច្បាប់។ តែក្រោយមកបែរជាកូនក្តីខ្លួនក្លាយជាជនត្រូវចោទអស់ប្រាក់បង់ពេលវេលាយ៉ាងងយុត្តិធម៌ទៅវិញ។ ដូច្នេះ សូម លោកចៅក្រមជំនុំជម្រះ មេត្តាលើកលែងបទចោទប្រកាន់លើកូនក្តីខ្លួនទាំងពីរ ព្រោះថាពួកគាត់មករស់នៅលើដីនេះក៏ព្រោះតែលិខិតលក់ផ្តាច់ ដែលធ្វើឡើងស្របតាមច្បាប់ និងថាកូនក្តីខ្លួនជាជនក្រីក្រប្រកបរបរឡើងត្នោត និងស៊ីឈ្នួលគេចិញ្ចឹមកូនជាច្រើននាក់ក្នុងបន្ទុក ពុំមានចំណេះដឹង ពុំមានទ្រព្យសម្បត្តិឯណាក្រៅពីដីមួយកន្លែងដែលទិញពីឈ្មោះ [redacted] សុផល នេះ។ សូម លោកចៅក្រមជំនុំជម្រះ មេត្តាផ្តល់យុត្តិធម៌ដោយលើកលែងចោទប្រកាន់ និងសម្របសម្រួលសំណងឬជាដីមួយចំណែកដើម្បីឱ្យកូនក្តីខ្លួនបានរស់នៅបន្តជីវភាព។

១១-សម្តីចុងក្រោយរបស់ជនជាប់ចោទ: សូមឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្ញុំបាទផង។

-ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] សាមិត្ត

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផន

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ីន និងឈ្មោះ [redacted] សុផា

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់ការធ្វើកំណត់សម្គាល់ខ្លីៗរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-តុលាការបានទទួលបណ្តឹងតាមដីកាសន្នដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ ១៤ /២០២៤ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៤ របស់អយ្យការអម សាលាដំបូងខេត្តកំពង់ឆ្នាំង ដែលបានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ហ៊ីន ភេទប្រុស អាយុ៥២ឆ្នាំ និងឈ្មោះ [redacted] សុផា ភេទស្រី អាយុ ៣៣ឆ្នាំ សញ្ជាតិខ្មែរ មកតុលាការដើម្បីជំនុំជម្រះពីបទ: **រំលោភកាន់កាប់អចលនវត្ថុដោយចេតនា** ប្រព្រឹត្តនៅភូមិស្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០២១ រហូតដល់បច្ចុប្បន្ន បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២៥៣ នៃច្បាប់ស្តីពីភូមិបាល។

២-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] សាមិត្ត បានឆ្លើយនៅដំណាក់កាលអយ្យការថា៖ ខ្លួនសូមជម្រាបតំណាងអយ្យការថាខ្លួនបច្ចុប្បន្នមានជំងឺត្រចៀកទាំងសងខាងដោយមិនអាចស្តាប់ឮបានទាំងស្រុង តែអាចអានអក្សរ និងនិយាយបាន។ ខ្លួនអាចអានសំណួរដែលតំណាងអយ្យការសរសេរដាក់ក្រដាស់បាន និងអាចឆ្លើយទៅតាមសំណួរវិញបាន។ ខ្លួនមិនចង់បានមេធាវីឡើយ ដោយសារតែខ្លួនគ្មានប្រាក់ជួលមេធាវី ហើយខ្លួនឱ្យកូនប្រសារខ្លួនឈ្មោះ [redacted] ផន ជាអ្នក

ដីងរឿងវិវាទដីនេះជាអ្នកតំណាងឱ្យខ្លួនក្នុងការប្ដឹងផ្ដល់។ ខ្លួនពិតជាជនរងគ្រោះក្នុងសំណុំរឿងខាងលើពិតប្រាកដមែន ដោយសារតែខ្លួនមានវ័យចាស់ជរា ភ្លេចភ្លាំងច្រើនមិនសូវចាំអ្វីច្រើន និងមានជំងឺត្រចៀកមិនអាចស្ដាប់បានទៀត ដូច្នេះហើយទើបបានជាខ្លួនឱ្យកូនប្រសារខ្លួនឈ្មោះ [redacted] ផន ភេទប្រុស អាយុ៦៤ឆ្នាំ ធ្វើជាដើមបណ្ដឹងជំនួសខ្លួនក្នុងសំណុំរឿងនេះ។ កន្លងមកខ្លួនពិតជាបានផ្ទេរសិទ្ធិឱ្យកូនប្រសារខ្លួនឈ្មោះ [redacted] ផន ដាក់ពាក្យបណ្ដឹងនានាលើរឿងវិវាទដីរបស់ខ្លួនឈ្មោះ ក្ដីចំនួន២កន្លែង គឺដីលំនៅដ្ឋានចំនួន១កន្លែង និងដីស្រែចំនួន១កន្លែង និងដីស្រែចំនួន១កន្លែង ដែលស្ថិតនៅភូមិស្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ពិតប្រាកដមែន។ ខ្លួនស្នើសុំឱ្យតំណាងអយ្យការអនុញ្ញាឱ្យកូនប្រសារខ្លួនឈ្មោះ [redacted] ផន ឆ្លើយបំភ្លឺនូវដំណើររឿងទាំងអស់ និងធ្វើជាដើមបណ្ដឹងក្នុងសំណុំរឿងខាងលើពីពេលនេះតទៅ ហើយខ្លួនសំណូមពរឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផងព្រមទាំងផ្ដន្ទាទោសជនល្មើសតាមច្បាប់។

៣-តាមចម្លើយរបស់ដើមបណ្ដឹងឈ្មោះ [redacted] ផន បានឆ្លើយថា៖ ខ្លួនត្រូវជាកូនប្រសាររបស់ឈ្មោះ [redacted] សាមិត្ត ដោយសារតែម្ដាយក្មេកខ្លួនបច្ចុប្បន្នមានជម្ងឺត្រចៀកទាំងសងខាង ដោយមិនអាចស្ដាប់ឮបានទាំងស្រុងហើយគាត់មានវ័យចាស់ជរាភ្លេចភ្លាំងច្រើន ទើបបានជាគាត់ផ្ទេរសិទ្ធិឱ្យ ខ្លួនធ្វើជាដើមបណ្ដឹងជំនួសគាត់ក្នុងរឿងក្ដីនេះ។ ចំពោះពាក្យបណ្ដឹងដែលខ្លួនបានប្ដឹងលើឈ្មោះ [redacted] ហ៊ុន, ឈ្មោះ [redacted] សុផា, ឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] ស្រីរ៉ាស់ ពាក់ព័ន្ធនឹងករណីហិង្សាទៅលើអ្នកកាន់កាប់ អចលនវត្ថុដោយសុចរិតនោះគឺដោយមូលហេតុថាតុលាការខេត្តកំពង់ឆ្នាំង ចេញដីកាសម្រេចអំពីរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹងលេខ ០៤/១៨ ដោយសម្រេចឱ្យម្ដាយក្មេកខ្លួនឈ្មោះ [redacted] សាមិត្ត ឈ្នះក្ដីក្នុងវិវាទដីដូចមានឯកសារភ្ជាប់ក្នុងពាក្យបណ្ដឹងរួចហើយ តែភាគីជនសង្ស័យឈ្មោះ [redacted] ហ៊ុន, ឈ្មោះ [redacted] សុផា, ឈ្មោះ [redacted] សុផល, និងឈ្មោះ [redacted] ស្រីរ៉ាស់ នៅមិនព្រមចាកចេញពីដីរបស់ម្ដាយក្មេកខ្លួនឡើយ ទើបបាន ជាម្ដាយក្មេកខ្លួនប្ដឹងឱ្យជនសង្ស័យទាំងអស់ចេញពីដីខាងលើនេះ។ សូមបញ្ជាក់បន្ថែមថាកាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ មេភូមិឈ្មោះ [redacted] សុទ្ធ បានមកហៅខ្លួនដល់ផ្ទះថា មេឃុំពង្រ ឱ្យទៅជួបនៅសាលាឃុំ លុះម៉ោង ១៣ ថ្ងៃត្រង់ ខ្លួនរង់ចាំរហូតដល់ម៉ោង ១៥ថ្ងៃត្រង់ ថ្ងៃខែឆ្នាំដដែល ក៏ឃើញឈ្មោះ [redacted] ឧត្តម នឹងឈ្មោះ រ៉ាត ចន្ថា ជាមេធាវីបានបើករថយន្តទៅដល់សាលាឃុំរួចភ្លាមនោះឈ្មោះ [redacted] ចន្ថា បានហៅខ្លួន ចូលទៅក្នុងបន្ទប់លោកមេឃុំពង្រ រួចបិទទ្វារដាក់គន្លឹះ ហើយឈ្មោះ [redacted] ឧត្តម បាននិយាយមកខ្លួនថា មាន ដឹងថាឯកសារផ្ទេរសិទ្ធិពីម្ដាយក្មេកមកឱ្យខ្លួនក្នុងការដាក់បញ្ដឹងមកស្នងការនឹងខុសឬអត់? ហើយខ្លួនក៏ឆ្លើយ ថាអត់ដឹងដែរតែមេឃុំជួយធ្វើឱ្យខ្លួន។ ពេលនោះឈ្មោះ [redacted] ឧត្តម បាននិយាយថាបើមិនចង់មានរឿងឱ្យខ្លួន ដកពាក្យបណ្ដឹងនៅស្នងការខេត្ត, កងរាជអាវុធហត្ថខេត្ត និងនៅតុលាការទៅលែងមានរឿងហើយ។ ពេល នោះខ្លួនក៏ឆ្លើយថា ខ្លួនមិនដឹងទេនៅលើតែតុលាការចាត់ចែង ហើយពេលនោះឈ្មោះ [redacted] ចន្ថា បានទាញ កុំព្យូទ័រវាយឯកសារដកពាក្យបណ្ដឹងឱ្យខ្លួនផ្ដិតមេដៃ ដោយពេលនោះឈ្មោះ [redacted] ឧត្តម បាននិយាយថា លោកមេឃុំ និងលោកមេភូមិបានធ្វើលិខិតមោឃៈភាពឯកសារកន្លងមកអស់ហើយ ដូច្នេះឱ្យខ្លួនត្រូវតែផ្ដិត មេដៃដកពាក្យបណ្ដឹងដូចគ្នាទៅ។ ពេលនោះខ្លួនមានការភ័យខ្លាចចេះតែផ្ដិតមេដៃតាមគេទៅ។ លុះក្រោយ មកថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ ខ្លួនក៏បានដាក់ពាក្យបណ្ដឹងមកអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង រួច ហើយ ដោយពាក្យបណ្ដឹងនោះចូលទៅលោក [redacted] រ៉ាន់នី ជាតំណាងអយ្យការទទួលដោះស្រាយរឿងបញ្ដាំង ឱ្យខ្លួន។ ដោយក្នុងបណ្ដឹងនោះខ្លួនបានប្ដឹងលើឈ្មោះ [redacted] ឧត្តម, ឈ្មោះ [redacted] ចន្ថា, ឈ្មោះ [redacted] ស្រីរ៉ាស, ឈ្មោះ [redacted] ហ៊ុន, និងឈ្មោះ [redacted] សុផា រួចហើយ។ ខ្លួនសំណូមពរដល់តំណាងអយ្យការជួយរកយុត្តិធម៌ ដល់ខ្លួនផង និងសុំឱ្យ



Scanned with CamScanner

ជនសង្ស័យខាងលើ ចេញពីដីម្តាយក្មេកខ្លួនវិញ។ ក្នុងរឿងនេះខ្លួនប្តឹងសុំទាមទារសំណងជំងឺចិត្តចំនួន ៥,០០០(ប្រាំពាន់) ដុល្លារអាមេរិក។

៤-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ីន បានឆ្លើយថា៖កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ខ្លួនបានទិញដីចំនួន ១កន្លែង មានទំហំទទឹង ៧ម៉ែត្រ x បណ្តោយ ៣៦ម៉ែត្រ ស្ថិតនៅចំណុចភូមិស្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដោយដីនេះខ្លួន និងប្រពន្ធ ខ្លួនបានទិញពីឈ្មោះ [redacted] សុផល ក្នុងតម្លៃ ២,០០០USD (ពីរពាន់ដុល្លារអាមេរិក) មុនពេលខ្លួន និងប្រពន្ធ ទៅទិញដីនេះខ្លួនបានទៅសួរមេភូមិឈ្មោះ [redacted] សុទ្ធ និងមេឃុំឈ្មោះ [redacted] សុផល ថាដីនេះមានបញ្ហាឬអត់ ហើយពួកគាត់ ថាមិនមានបញ្ហាអ្វីឡើយ ដោយគាត់បានចុះហត្ថលេខាលើលិខិតទិញលក់ត្រឹមត្រូវពេលទិញ រួចហើយខ្លួន និងប្រពន្ធបានសង់ខ្ទមរស់នៅរហូតដល់បច្ចុប្បន្ន។ ទើបនៅក្នុងអំឡុងឆ្នាំ២០១៨ មានខាង សុរិយោដីខេត្តចុះមកវាស់វែងធ្វើប្លង់ ពេលនោះខ្លួនបានទៅសួរអាជ្ញាធរភូមិឃុំ ថាហេតុអ្វីគេមិនវាស់វែងដីឱ្យ ខ្លួនពេលនោះអាជ្ញាធរឆ្លើយថារឿងនេះគាត់នឹងពិភាក្សាគ្នាជាមួយខាងសុរិយោដីខេត្តសិន ក្រោយមកខ្លួនបាន ទៅជួបសុរិយោដីគេក៏បានហៅខ្លួនហៅឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] សាមិត្ត ដើម្បីទៅសម្រុះសម្រួល ពេលនោះឈ្មោះ [redacted] សាមិត្ត បានព្រមព្រៀងប្រគល់ដីខាងលើទំហំ ៧ម៉ែត្រ x ៣៦ម៉ែត្រ មកឱ្យខ្លួនហើយតែ ឈ្មោះ [redacted] សុផល មិនឯកភាពក៏ការសម្របសម្រួលនេះមិនបានលទ្ធផល។ ពេលខ្លួនទិញដីនេះដំបូងខ្លួនមិន ដឹងថាឈ្មោះ [redacted] សុផល យកដីជាទ្រព្យរបស់ប្រពន្ធគាត់ដែលពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាតាម ច្បាប់មកលក់ឱ្យខ្លួនឡើយ បើសិនជាខ្លួនដឹងក៏ខ្លួនមិនទិញដីខាងលើនេះដែរ។ ចំពោះដី និងខ្ទមដែលខ្លួន កំពុងរស់នៅជាមួយប្រពន្ធកូននេះគឺខ្លួនមិនអាចចុះទៅរស់នៅទីណាផ្សេងបានឡើយព្រោះខ្លួនមានតែដី និងខ្ទមមួយនេះសម្រាប់រស់នៅតែប៉ុណ្ណោះដោយពុំមានកន្លែងរស់នៅផ្សេងទៀតឡើយ។ ក្នុងរឿងខាងលើ នេះខ្លួនពុំបានប្តឹងឈ្មោះ [redacted] សុផល នោះទេដោយឃើញពីស្ថានភាពគ្រួសារ របស់ឈ្មោះ [redacted] សុផល មានការ លំបាក រីឯឈ្មោះ [redacted] សុផល កំពុងជាប់ពន្ធនាគារពាក់ព័ន្ធនឹងដីវិវាទខាងលើនេះទៀត។ ក្នុងរឿងនេះខ្លួនសុខចិត្ត ចាកចេញពីដីខាងលើឱ្យបានមុន ថ្ងៃប្រកាសសាលក្រម គឺថ្ងៃទី០២ ខែមេសា ឆ្នាំ២០២៤។

៥-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុផា បានឆ្លើយថា៖កាលពីអំឡុងឆ្នាំ២០១៥ ខ្លួន និងប្តីឈ្មោះ [redacted] ម ហ៊ីន បាននាំគ្នាមកជួលដីរបស់ឈ្មោះ [redacted] សុផល ដើម្បីធ្វើ ផ្ទះរស់នៅបណ្តោះអាសន្ន ដោយជួលក្នុងរយៈពេល១ឆ្នាំពេញ ដែលមានតម្លៃចំនួន ២៤០,០០០៛ (ម្ភៃបួន ម៉ឺនរៀល) ដែលដីខាងលើស្ថិតនៅភូមិស្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដោយមានវត្តមាន ឈ្មោះ [redacted] សុផល និងប្រពន្ធឈ្មោះ [redacted] សាមៀន រស់នៅជិតពួកខ្លួនដែរ បន្តរហូតដល់ឆ្នាំ២០១៧ រូបខ្លួន និងប្តីចាប់ផ្តើមពិភាក្សាដោយចង់ទិញដីនៅចំណុចខាងលើ ពេលដែលសួរនាំឈ្មោះ [redacted] សុផល ក៏បានព្រមព្រៀងលក់ឱ្យរូបខ្លួន និងប្តីដោយដីទំហំទទឹង ៧ម៉ែត្រ និងបណ្តោយ ៣៧ម៉ែត្រ ក្នុងតម្លៃ ១០,០០០,០០០៛ (ដប់លានរៀល) អំឡុងពេលដែលលក់ដីឈ្មោះ [redacted] សុផល ព្រមព្រៀងលក់តែម្នាក់ឯងទេ គឺប្រពន្ធឈ្មោះ [redacted] សាមៀន បានស្លាប់ហើយ ក្នុងការទិញដីរបស់ឈ្មោះ [redacted] សុផល រូបខ្លួន និងប្តីគឺធ្វើឯកសារត្រឹមភូមិឃុំទេ ដោយមានមេភូមិឈ្មោះ [redacted] សុទ្ធ និងមេឃុំឈ្មោះ [redacted] សុផល ជាអ្នកចុះហត្ថលេខា លើឯកសារដី រូបខ្លួន និងប្តីទទួលស្គាល់ថាពិតជាបានទិញដីពីឈ្មោះ [redacted] សុផល ពិតប្រាកដមែន និងបានរស់នៅលើដីដោយ ធ្វើរោងសម្រាប់រស់នៅបណ្តោះអាសន្ន រហូតដល់បច្ចុប្បន្នពិតប្រាកដមែន។ ក្នុងរឿងនេះខ្លួនសុខចិត្ត ចាកចេញពីដីខាងលើឱ្យបានមុន ថ្ងៃប្រកាសសាលក្រម គឺថ្ងៃទី០២ ខែមេសា ឆ្នាំ២០២៤។



Scanned with CamScanner

៦-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយរបស់សាក្សី និងកំណត់ហេតុនានានៅក្នុងសំណុំរឿង ពេលសវនាការរួចមកឃើញថា: កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្ថិតនៅភូមិក្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ឈ្មោះ [redacted] សុផល ពិតជាបានលួចលក់ដីដែល ជាកម្មសិទ្ធិរបស់ជនរងគ្រោះឈ្មោះ [redacted] សាមិត្ត លក់ទៅឱ្យទៅឈ្មោះ [redacted] ហ៊ុន ភេទប្រុស និងឈ្មោះ [redacted] សុផា អស់ទំហំ៧ ម៉ែត្រ និងបណ្តោយ ៣៥ម៉ែត្រ ក្រោយមកជនរងគ្រោះឈ្មោះ [redacted] សាមិត្ត ក៏បានដាក់ពាក្យប្តឹងលើឈ្មោះ [redacted] សុផល ហើយត្រូវបានតុលាការខេត្តកំពង់ឆ្នាំងសម្រេចផ្តន្ទាទោសតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ១២ “ខ” ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ដាក់ពន្ធនាគារកំណត់រយៈពេល ១ (មួយ) ឆ្នាំ ពីបទ លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន ដោយឡែកឈ្មោះ ញ៉ែម ហ៊ុន និងប្រពន្ធឈ្មោះ [redacted] សុផា ដែលបានទិញ ដីពីឈ្មោះ [redacted] សុផល ក៏ត្រូវបានឈ្មោះ [redacted] សាមិត្ត ប្តឹងពីបទ កាប់បំផ្លាញដើមត្នោត និងដើមអំពិល នៅលើដីដែលបានទិញនោះអស់ចំនួន ០៤ ដើម រហូតដល់តុលាការខេត្តកំពង់ឆ្នាំងសម្រេចផ្តន្ទាទោសអ្នកទាំងពីរ ដាក់ពន្ធនាគារចំនួន ៦ (ប្រាំមួយ) ខែ ក្នុងម្នាក់ៗតែទោសនេះត្រូវអនុវត្តព្យួរធម្មតា ពីបទ ធ្វើឱ្យខូចខាត ដោយចេតនា ប្រព្រឹត្តនៅចំណុចភូមិស្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១២ ខែ ឧសភា ឆ្នាំ២០២១ តាមសាលក្រមព្រហ្មទណ្ឌលេខ ១៨៧ “ច” ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ តែទោះបីជា តុលាការបានសម្រេចសេចក្តីរួចហើយក៏ដោយក៏ឈ្មោះ [redacted] ហ៊ុន និងឈ្មោះ [redacted] សុផា នៅតែមិនចាកចេញ និងបានកាន់កាប់ដីលើទីតាំងដែលបានទិញដោយខុសច្បាប់នោះរហូតមកដល់សព្វថ្ងៃ ប្រាកដមែន។ ក្នុងករណីដែលជនជាប់ចោទព្រមចាកចេញពីដីទំនាស់ខាងលើដោយស្ម័គ្រចិត្ត តំណាងអយ្យការប្តឹងសុំឱ្យតុលាការសម្រេចឱ្យជនជាប់ចោទពីរនាក់រួចខ្លួនពីបទចោទៈ ប៉ុន្តែបើជនជាប់ចោទមិនព្រមចាកចេញពីដីទំនាស់ខាងលើទេនោះ តំណាងអយ្យការប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទទាំងពីរឱ្យធ្ងន់ធ្ងរតាមច្បាប់ និងប្តឹងសុំឱ្យតុលាការចេញដីកាបង្គាប់ឱ្យចាប់ខ្លួន និងឃុំខ្លួន។ គប្បីចៅក្រមជំនុំជម្រះសម្រេចអំពីការប្តឹងសុំនេះ។

៧-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការរួចមកឃើញថា កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ កូនក្តីខ្លួនឈ្មោះ [redacted] ហ៊ុន និងប្រពន្ធឈ្មោះ [redacted] សុផា បានធ្វើលិខិតលក់ដីមួយកន្លែងនៅភូមិស្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ជាមួយឈ្មោះ [redacted] សុផល ក្នុងតម្លៃ២,០០០(ពីរពាន់)ដុល្លារអាមេរិក ស្របទៅតាមច្បាប់ គឺធ្វើជាលិខិតលក់ផ្តាច់ លេខ ៤០៨/០១៧ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ របស់សាលាឃុំពង្រ។ ប៉ុន្តែក្រោយមកទៀតក៏ដឹងថាឈ្មោះ [redacted] សុផល ពុំមែនជាម្ចាស់កម្មសិទ្ធិលើដីលក់នោះទេ តាមពិតដីនេះជាដីរបស់ឈ្មោះ [redacted] សាមិត្ត ជាប្អូនរបស់ឈ្មោះ [redacted] សាមៀន ត្រូវជាអតីតប្រពន្ធឈ្មោះ [redacted] សុផល។ ក្រោយមកទៀតកូនក្តីខ្លួនឈ្មោះ [redacted] ហ៊ុន និងប្រពន្ធឈ្មោះ [redacted] សុផា បានត្រូវឈ្មោះ កែ សាមិត ប្តឹងផ្តល់មិនចេះអស់មិនចេះហើយ ក្នុងគោលបំណងឱ្យកូនក្តីខ្លួនចេញពីដីដែលជាកម្មវត្ថុទិញលក់ខាងលើ។ គួរ បញ្ជាក់ដែរថា ពេលទិញលក់កូនក្តីខ្លួនពុំបានដឹងទេថាឈ្មោះ [redacted] សុផល ពុំមែនជាម្ចាស់ដី និងជឿជាក់យ៉ាងមុតមាំថាដីនេះជារបស់ឈ្មោះ [redacted] សុផល ព្រោះអាជ្ញាធរភូមិឃុំនៅទីនោះបានធ្វើលិខិតទិញលក់ដោយមានវាយត្រាចុះលេខត្រឹមត្រូវស្របទៅតាមច្បាប់។ តែក្រោយមកបែរជាកូនក្តីខ្លួនក្លាយជាជនត្រូវចោទអស់ប្រាក់បង់ពេលវេលាយ៉ាងអយុត្តិធម៌ទៅវិញ។ ដូច្នេះ សូម លោកចៅក្រមជំនុំជម្រះ មេត្តាលើកលែងបទចោទប្រកាន់លើកូនក្តីខ្លួនទាំងពីរ ព្រោះថាពួកគាត់មករស់នៅលើដីនេះក៏ព្រោះតែ

លិខិតលក់ផ្តាច់ ដែលធ្វើឡើងស្របតាមច្បាប់ និងថាកូនក្តីខ្លួនជាជនក្រីក្រប្រកបរបរឡើងត្នោត និងស៊ីឈ្នួលគេ ចិញ្ចឹមកូនជាច្រើននាក់ក្នុងបន្ទុក ពុំមានចំណេះដឹង ពុំមានទ្រព្យសម្បត្តិឯណាក្រៅពីដីមួយកន្លែងដែលទិញពីឈ្មោះ [redacted] សុផល នេះ។ សូម លោកចៅក្រមជំនុំជម្រះ មេត្តាផ្តល់យុត្តិធម៌ដោយលើកលែងចោទប្រកាន់ និងសម្របសម្រួលសំណង ឬជាដីមួយចំណែកដើម្បីឱ្យកូនក្តីខ្លួនបានរស់នៅបន្តជីវភាព។

៨-ចំពោះដីវិវាទគឺជាដីរបស់ឈ្មោះ [redacted] សាមិត ដូចមានបញ្ជាក់ក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ០៤០៦០៧០៣-១០៥៦ និងលេខ ០៤០៦០៧០៣-០៩៧៧ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ ហើយជនជាប់ចោទឈ្មោះ [redacted] ហ៊ឺន ភេទប្រុស អាយុ ៥២ឆ្នាំ និងឈ្មោះ [redacted] សុផា ភេទស្រី អាយុ ៣៣ឆ្នាំ បានរស់នៅលើដីនេះ ទោះបីដឹងថាដីនេះជាដីកម្មសិទ្ធិរបស់ឈ្មោះ [redacted] សាមិត។ ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទ, ជនរងគ្រោះ, ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី គឺមានភាពស៊ីសង្វាក់គ្នាជាមួយរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងនានានៅក្នុងសំណុំរឿងដែលបញ្ជាក់បានថា: ជនជាប់ចោទឈ្មោះ [redacted] ហ៊ឺន ភេទប្រុស អាយុ ៥២ឆ្នាំ និងឈ្មោះ [redacted] សុផា ភេទស្រី អាយុ ៣៣ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ **រំលោភកាន់កាប់អចលនវត្ថុដោយចេតនា** ប្រព្រឹត្តនៅភូមិស្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ រហូតដល់បច្ចុប្បន្ន ប្រាកដមែន។

៩-ជនជាប់ចោទឈ្មោះ [redacted] ហ៊ឺន និងប្រពន្ធឈ្មោះ ធីម សុផា បានឆ្លើយនៅពេលសវនាការថា៖ ក្នុងរឿងនេះខ្លួនសុខចិត្ត ចាកចេញពីដីខាងលើឱ្យបានមុន ថ្ងៃប្រកាសសាលក្រម គឺថ្ងៃទី០២ ខែមេសា ឆ្នាំ២០២៤ ប៉ុន្តែរហូតដល់ថ្ងៃប្រកាសសាលក្រម ជនជាប់ចោទទាំងពីរនាក់ខាងលើនៅតែមិនព្រមចាកចេញពីដីទំនាស់ខាងលើដដែល បើផ្អែកតាមកំណត់ហេតុចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៤។

១០-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ឺន ភេទប្រុស អាយុ ៥២ឆ្នាំ និងឈ្មោះ [redacted] សុផា ភេទស្រី អាយុ ៣៣ឆ្នាំ គឺជាចេតនាទុច្ចរិតដើម្បីចូលកាន់កាប់ទ្រព្យសម្បត្តិរបស់អ្នកដទៃយកធ្វើជាកម្មសិទ្ធិរបស់ខ្លួនឯង ដោយមិនស្របច្បាប់ ដែលអំពើនេះជាបទល្មើសព្រហ្មទណ្ឌ មានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤៨ និងមាត្រា ២៥៣ នៃច្បាប់ស្តីពីភូមិបាល។

១១-មានធាតុផ្សំ និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ហ៊ឺន ភេទប្រុស អាយុ ៥២ឆ្នាំ និងឈ្មោះ [redacted] សុផា ភេទស្រី អាយុ ៣៣ឆ្នាំ សញ្ជាតិខ្មែរ ពីបទ **រំលោភកាន់កាប់អចលនវត្ថុដោយចេតនា** ប្រព្រឹត្តនៅភូមិស្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ រហូតដល់បច្ចុប្បន្ន បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៤៨ និងមាត្រា ២៥៣ នៃច្បាប់ស្តីពីភូមិបាល។

១២-ជនជាប់ចោទឈ្មោះ [redacted] ហ៊ឺន ភេទប្រុស អាយុ ៥២ឆ្នាំ និងឈ្មោះ [redacted] សុផា ភេទស្រី អាយុ ៣៣ឆ្នាំ សញ្ជាតិខ្មែរ ជានីតិជន មានសតិសម្បជញ្ញៈគ្រប់គ្រាន់ អាចយល់ដឹងពីផលប៉ះពាល់ដែលបណ្តាលមកពីទង្វើរបស់ខ្លួន ដែលទង្វើទាំងនេះបានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ហើយអំពើទាំងនេះត្រូវបានច្បាប់ការពារយ៉ាងតឹងរ៉ឹងបំផុត និងត្រូវទទួលទោសជាធរមាន។



Scanned with CamScanner

១៣-ដើមបណ្តឹងឈ្មោះ [redacted] ផន បានប្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីទាមទារសំណងជំងឺចិត្តពីជនជាប់ចោទ ចំនួន ៥,០០០(ប្រាំពាន់)ដុល្លារអាមេរិក។ ហេតុនេះ គប្បីតុលាការ ពិនិត្យ ពិចារណា និងសម្រេច តាមព្យសនកម្មកើតឡើងជាក់ស្តែង។

## ហេតុដូច្នេះសម្រេច

១/- ផ្តន្ទាទោសលើជនជាប់ចោទ៖

ឈ្មោះ [redacted] ហ៊ីន ភេទប្រុស អាយុ ៥២ឆ្នាំ សញ្ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ)

ឈ្មោះ [redacted] សុផា ភេទស្រី អាយុ ៣៣ឆ្នាំ សញ្ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ)

**ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ចំនួន ០១(មួយ)ឆ្នាំ។**

ពីបទ៖ **រំលោភកាន់កាប់អចលនវត្ថុដោយចេតនា** ប្រព្រឹត្តនៅភូមិស្រាំងខ្ពស់ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ រហូតដល់បច្ចុប្បន្ន បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៤៨ និងមាត្រា ២៥៣ នៃច្បាប់ស្តីពីភូមិបាល។

២/-អោយជនជាប់ចោទឈ្មោះ [redacted] ហ៊ីន ភេទប្រុស និងជនជាប់ចោទឈ្មោះ [redacted] សុផា ភេទស្រី រួមគ្នាសងសំណងជំងឺចិត្ត ៦,០០០,០០០(ប្រាំមួយលាន)រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផន។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទ និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០២៤ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា
[redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា
[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃ អង្គារ ៩រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
កំពង់ឆ្នាំង, ថ្ងៃទី០២ ខែមេសា ឆ្នាំ២០២៤
**ក្រឡាបញ្ជី**
[redacted]

បានឃើញ និងឯកភាព
**ចៅក្រមជំនុំជម្រះ**
[redacted]



Scanned with CamScanner